BMI0050

# សម្ភាសន៍ជាមួយឈ្មោះ ញ៉ូស ខុម ភេទស្រី អាយុ៥២ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“ យោធាកាន់ខាងសាំង”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិវត្ត ឃុំខ្នារឆ្នា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៨:២៦

២០ទំព័រ

វណ្ណៈៈ ចឹងសូមណែនាំខ្លួនថាខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ខុម ៈ ចាស ។

វណ្ណៈៈ ហើយខ្ញុំមកដល់ម៉ាឡៃគឺចង់សរសេរសៀវភៅមួយទាក់ទងនិងស្រុកម៉ាឡៃ ថាយើងអភិវឌ្ឍន៍យ៉ាងម៉េច កាលពីមុនប្តូថាមានព្រៃស្រោងចាំមីងរៀបរាប់ហើយមីងពីភ្នំពេញកាលឆ្នាំ៧៩ជួបការលំបាកយ៉ាងម៉េច?

ខុម ៈ ចាស ។

វណ្ណៈៈ ប្រវត្តិរបស់មីងកាលពីតូចរៀនអីបានយ៉ាងម៉េច ចាំមីងជួយរៀបរាប់?

ខុម ៈ ចាស ។

វណ្ណៈៈ ចឹងព័ត៌មានទាំងអស់ហ្នឹងខ្ញុំសុំការអនុញ្ញាតពីមីង យកទៅសរសេរជាសៀវភៅមីងមិនថាអីទេ?

ខុម ៈ ចាស ។

វណ្ណៈៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីទៅ?

ខុម ៈ ឈ្មោះ ញ៉ូស ខុម ។

វណ្ណៈៈ មីងអាយុប៉ុន្មានហើយ?

ខុម ៈ អាយុ៥២ឆ្នាំ ។

វណ្ណៈៈ ប្តីមីងឈ្មោះអីដែរ?

ខុម ៈ ឈ្មោះ សាន់ ឡឿន ។

វណ្ណៈៈ គាត់អាយុប៉ុន្មានហើយ?

ខុម ៖ ឪវា៩៥ដឹង៩៦មិនដឹងទេ ។

វណ្ណៈ ចឹងសព្វថ្ងៃមានកូនប៉ុន្មាននាក់?

ខុម ៖ មានកូនបីនាក់ ។

វណ្ណៈ ស្រីទាំងអស់?

ខុម ៖ ស្រីពីរប្រុសមួយ ។

វណ្ណៈ ឪពុកមីងឈ្មោះអីដែរ?

ខុម ៖ ឈ្មោះ ញ៉ូស ញិល ។

វណ្ណៈ ម្ដាយ?

ខុម ៖ ឈ្មោះ ពេជ ហៃ ។

វណ្ណៈ ចឹងគាត់ទាំងពីរនៅរស់ទេ?

ខុម ៖ គាត់ស្លាប់ហើយ ។

វណ្ណៈ ស្រុកកំណើតមីង?

ខុម ៖ ស្រុកកំណើតខ្ញុំនៅកំពង់ឆ្នាំង ។

វណ្ណៈ ភូមិ?

ខុម ៖ ភូមិវត្ត ។

វណ្ណៈ ឃុំ

ខុម ៖ ឃុំខ្នាឆ្មា ។

វណ្ណៈ ស្រុក?

ខុម ៖ ពីដើមគេហៅកំពង់ត្រឡាច ឥឡូវគេដាក់សាមគ្គីមានជ័យ ។

វណ្ណៈ ចឹងពីដើមស្រុកំពង់ត្រឡាច?

ខុម ៖ ចាស!កំពង់ត្រឡាចលើ ។

វណ្ណៈ ខេត្តកំពង់ឆ្នាំង?

ខុម ៖ ចាស ។

វណ្ណៈ ចឹងឥឡូវនៅភូមិ?

ខុម ៖ នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ចឹងមុខរបរសព្វថ្ងៃ?

ខុម ៖ ខ្ញុំធ្វើស្រែចំការ ។

វណ្ណៈ ចឹងមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

ខុម : បងប្អូនបង្កើតខ្ញុំមាន៦នាក់ ។

វណ្ណៈ: ចឹងមាន៦នាក់?

ខុម : ចាស! តែស្លាប់អស់នៅសល់តែបីនាក់ ។

វណ្ណៈ: ស្លាប់បីនាក់នៅជំនាន់ណា?

ខុម : ស្លាប់ឆ្នាំទៅមិញមួយ ស្លាប់កាលផ្តាច់ខ្លួននោះមួយ ។

វណ្ណៈ: ចឹងស្លាប់ក្រោយ៧៩?

ខុម : ចាស ។

វណ្ណៈ: ចឹងខ្ញុំចង់ឲ្យមីងនិយាយរៀបរាប់រឿងរ៉ាវដែលធ្លាប់ឆ្លងកាត់មក និយាយតាំងពីតូចរៀនបានត្រឹមណាហើយនៅកន្លែងណាធ្វើអីខ្លះ?

ខុម : ចាស! កាលនៅតូចក្រណាស់នៅជាមួយឪពុកម្តាយខ្ញុំដែរ មិនដែលហូបគ្រប់ទេ មិនដែលមានស្លៀកពាក់បានដូចគេទេ ។

វណ្ណៈ: ចឹងកាលហ្នឹងរៀន?

ខុម : រៀនកាលហ្នឹងថ្នាក់ទី៩ មិនបានត្រឹមណា ដល់មានរដ្ឋប្រហារទៅខានរៀនទៅ ដល់ចូលដល់ឆ្នាំណាទេ សង្គ្រាមសម័យលន់ នល់នោះក៏មិនបានរៀនដែលកាលហ្នឹង អត់បានរហូតនៅជួយធ្វើស្រែចំការម៉ែ ។

វណ្ណៈ: ចឹងនៅពេលឆ្នាំ៧៥ខ្មែរក្រហមចូលមកមីងទៅណាទៀត?

ខុម : ៧៥ខ្មែរក្រហមចូលមកខ្ញុំនៅស្រុក ។

វណ្ណៈ: នៅស្រុកហ្នឹងមីងមានធ្វើអី?

ខុម : អត់មានធ្វើអីទេ នៅធ្វើស្រែនៅផ្ទះហ្នឹង ។

វណ្ណៈ: មីងនៅកងចល័ត?

ខុម : កាលកងចល័តខ្ញុំនៅចេញពីកងចល័តមកអង្គការឲ្យចេញមកនៅសៀមរាប ។

វណ្ណៈ: ចឹងបន្ទាប់មកទៀត?

ខុម : អង្គការហៅមកនៅលផ្អែកចេញពីលផ្អែកបានមកនៅសៀមរាប ។

វណ្ណៈ: ចឹងលផ្អែកហ្នឹងធ្វើអី?

ខុម : នៅកងនារី ។

វណ្ណៈ: ចឹងនៅបានរយៈពេលប៉ុន្មាន?

ខុម : នៅប្រហែលជាពីរទៅបីខែអង្គការឲ្យមកនៅសៀមរាបវិញ ។

វណ្ណៈ: ចឹងពីណាជាអ្នកឲ្យមក?

ខុម ៖ អង្គការជាអ្នកជ្រើសឈ្មោះមក ។

វណ្ណៈ ចឹងកាលហ្នឹងប្រធាននៅសៀមរាបពីណាគេ?

ខុម ៖ ប្រធានខ្ញុំខ្មោចបងណាងគាត់ស្លាប់ហើយ ។

វណ្ណៈ គាត់មានតួនាទីប៉ុណ្ណា?

ខុម ៖ បងណាង គាត់ក្តាប់នារីនៅខេត្តសៀមរាប ។

វណ្ណៈ ចឹងមីងធ្វើអីនៅសៀមរាបហ្នឹង?

ខុម ៖ ខ្ញុំនៅកន្លែងកាន់សាំង និងដាំបាយឲ្យអ្នកកាន់សាំងទាំងអស់និងអ្នកនៅមន្ទីរ ។

វណ្ណៈ មន្ទីរហ្នឹងជាមន្ទីរស្អីគេ?

ខុម ៖ មន្ទីររួមដូចជាពូៗកាន់សាំងហ្នឹង ។

វណ្ណៈ ដូចខាងយោធាអីហ្នឹង?

ខុម ៖ ចាស ។

វណ្ណៈ ចឹងមានប៉ុន្មានរយនាក់ទៅ?

ខុម ៖ ប៉ុន្មានប្រហែលជា១០០នាក់ហ្នឹងឯង ដាំបាយពីរខ្ទះ កាលសម័យហ្នឹងមានបាយខ្ទះបបរខ្ទះ ។

វណ្ណៈ ចឹងកាលហូបចុកយ៉ាងម៉េចដែរ?

ខុម ៖ កាលហូបចុកគ្រប់គ្រាន់ទេ កាលណីនៅចល័តបានពិបាកអត់មានអីហូបចុកទេ ។

វណ្ណៈ ចឹងពេលចូលមិត្តនារីទៅហូបចុកមិនលំបាកទេ?

ខុម ៖ ចាស! បានបបរព្រឹកបាយល្ងាច នៅឆ្នាំ៧៩ពិបាកមែន នៅពេលរត់ហ្នឹង ។

វណ្ណៈ កាលហ្នឹងកាន់សាំងហ្នឹងចាក់ឲ្យខាងណា?

ខុម ៖ កាលនៅជាមួយអង្គការមិនដឹងចាក់ឲ្យខាងទេ ខ្ញុំចាំកាន់កន្លែងកាន់សាំងនៅផ្លូវបាត់ដំបងមកខាងនេះមក ខ្ញុំនៅផ្លូវស្របនេះដាំបាយនៅស្របមាត់ស្ទឹងសៀមរាបហ្នឹងជិតស្ពានថ្ម ។

វណ្ណៈ ចឹងនៅសៀមរាបហ្នឹងមានដែលឃើញកែវ ពកទេ?

ខុម ៖ មិនដែលឃើញទេ ឃើញតែអ៊ឹប៉ុល ពត ។

វណ្ណៈ គាត់មកធ្វើអី?

ខុម ៖ ខ្ញុំមិនដែលឃើញនៅទីនេះទេ តែគាត់មកទស្សនៈកិច្ចនៅព្រលានយន្តហោះ ខ្ញុំបានទៅទទួលនៅហ្នឹង ។

វណ្ណៈ ឃើញពីណាខ្លះ?

ខុម ៖ ឃើញតា ប៉ុល ពតហ្នឹង ហើយជនបរទេសមិនដឹងជាប៉ុន្មានប្រទេសទេ មកកាលហ្នឹង ។

វណ្ណៈ ប្រហែលជាឆ្នាំណា?

ខុម ៖ មុនពេលយើងរត់យួន បានប្រហែលជាពីរទៅបីខែ ។

វណ្ណៈ ចឹងឆ្នាំ៧៨?

ខុម ៖ ចាស ។

វណ្ណៈ ចឹងមានឃើញអ្នកកាសែតទេ?

ខុម ៖ មានអ្នកកាសែត មានកងការពារគេច្រើនណាស់ ឃើញតែប៉ុណ្ណឹងឯងគ្នាច្រើនដែរ ។

វណ្ណៈ ចឹងកាលនៅសៀមរាបហ្នឹងមានឃើញភ្ញៀវបរទេសចេញចូលប្តូរមួយយ៉ាងម៉េចដែរ?

ខុម ៖ ភ្ញៀវមិនដឹងជាយ៉ាងម៉េច បើខ្ញុំនៅតែកន្លែងខ្ញុំមិនដែលបានដើរផង រកតែម្ហូបបន្លែស្លមិនដែលបានដើរទេ តែអង្គរវត្តមិនដែលបានទៅផង ។

វណ្ណៈ ចឹងនៅសៀមរាបហើយមិនដែលបានទៅលេងអង្គ?

ខុម ៖ ចាស!មិនដែលបានទៅដល់ទេ ខ្ញុំកាលនោះមិនចេះជិះកង់ផង សម័យនោះមិនចេះជិះកង់ អ្នកជិះកង់គេទៅកើបអាចម៍ត្រចៀវពីអង្គរវត្តហ្នឹងមកធ្វើជីសម្រាប់ដាក់ស្រែ ខ្ញុំអត់ចេះជិះគេមិនឲ្យទៅទៅណាទាល់តែគេឌុប បានតែដើរជុំវិញក្រុងប៉ុណ្ណោះឯង ។

វណ្ណៈ ចឹងនៅសៀមរាបហ្នឹងមានភ្ញៀវចេញចូលច្រើនទេតាមមីងដឹង?

ខុម ៖ មានដឹង ខ្ញុំមិនដែលដឹងដែរ បើមានភ្ញៀវមកមានគេទៅទទួលណាស់ ទៅទទួលនៅព្រលានយន្តហោះតែកាលហ្នឹងខ្ញុំបានទៅទទួលតែម្តងទេ ។

វណ្ណៈ ចឹងកាលហ្នឹងនៅសៀមរាបគេហៅភូមិភាគអី?

ខុម ៖ ខ្ញុំមិនដឹងថាជាភូមិភាគអីទេ ។

វណ្ណៈ ចឹងតំបន់?

ខុម ៖ ខ្ញុំមិនដឹងថាជាតំបន់អីទេ ខ្ញុំនៅសម័យនោះខ្ញុំមិនបានដឹងដែរ ខ្ញុំគេដឹងពីកំពង់ឆ្នាំងទៅដែរ ។

វណ្ណៈ ចឹងមីងនៅសៀមរាបរហូតដល់ឆ្នាំ៧៩?

ខុម ៖ ចាស! ហើយខ្ញុំរត់នៅឆ្នាំ៧៩ហ្នឹងតែម្តង ។

វណ្ណៈ ៧៩ពេលយួនចូលមកហ្នឹង?

ខុម ៖ ចាស ។

វណ្ណៈ ហេតុអីបានជាមីងរត់ទៅផ្ទះ?

ខុម ៖ កាលហ្នឹងមុនខ្ញុំរត់មកហ្នឹងដាំបាយទទួលពេញផ្ទះ ដល់យួនចូលមកខ្ញុំមិនដឹងជារត់ទៅណាខ្ញុំត្រៀមឡើងពេញមួយយប់ ដល់ពេលនេះខ្ញុំងើបដាំបាយ ដាំបាយហើយនៅតែខ្ញុំពីរនាក់ទេ ដល់ចឹងទៅកាំភ្លើងគេបាញ់មក ខ្ញុំរត់មកនៅក្រោយសាំងសៀមរាបហ្នឹងហើយចេញមកបាត់ដំបង ។

វណ្ណៈ បាទ ។

ខុម ៖ ដល់ពេលនេះគេរត់ចេញពីក្រុងអស់ នៅតែខ្ញុំហ្នឹងចឹងឃើញបង១ នៅកន្លែងទទួលភ្ញៀវគេហៅឡើងមកចេះតែជិះលិចមកលិចមក កាលហ្នឹងបែកអង្គភាពហើយខ្ញុំ ចឹងចេះតែជិះតាមគេរហូតមិនដឹងជាដល់ណាដល់ណីទេ មកជួបគ្នាតាមព្រំដែននេះ មកលើភ្នំដងរែកមកលើភូមិអំពិលភូមិអីណាទេ ខ្ញុំនៅកន្លែងកាន់ឃ្លាំង ខ្ញុំកាន់ឃ្លាំង ។

វណ្ណៈ៖ បាទ ។

ខុម ៖ កាន់ឃ្លាំងគ្រាប់តែមិនបានធ្វើអីទេ ពេលយាមទៅដើរដាក់ទៅ ដាក់ហើយជញ្ជូនចេញមានអាត្រាក់មានឡាន កាលហ្នឹងមានអង្គរបុកហើយរត់ចេញពី៧៩ហ្នឹង រត់មកចេញមកច្រកប៉ោយប៉ែតទួលជ្រាលនេះ យើងអស់មានឡានមានអាត្រាក់ហើយ ចាប់ផ្ដើមដើរមករហូតមកចេញច្រកប៉ោយប៉ែតមកដល់ទំនប់ដាច់ហ្នឹងមកតាមព្រំដែនហ្នឹងរហូត ។

វណ្ណៈ៖ ចឹងកាលហ្នឹងរត់ទៅខាងប៉ោយប៉ែតវិញ?

ខុម ៖ ចេញតាមច្រកហ្នឹងមិនដឹងជាខាងណាទេ គេថាជិតប៉ោយប៉ែត តាមទំនប់ម៉ក់ហ៊ុនហ្នឹងមក ។

វណ្ណៈ៖ ចឹងកាត់ទំនប់ម៉ក់ហ៊ុន?

ខុម ៖ ចាស!កាត់ទំនប់ហ្នឹងខាងលិចមក ត្រូវយើង៥០២កូនដីរហ្នឹង ។

វណ្ណៈ៖ ចឹងជំនាន់ខ្មែរក្រហមមានលើកទំនប់ម៉ក់ហ៊ុនមួយដែរ?

ខុម ៖ ចាស!ទំនប់ម៉ក់ហ៊ុនហ្នឹងគេហៅតែទំនប់កាច់ ។

វណ្ណៈ៖ ចឹងទំនប់ហ្នឹងមីងមានបានមកលើកទេ?

ខុម ៖ មិនបានមកលើកទេ ។

វណ្ណៈ៖ ចឹងប្រជាជនលើក?

ខុម ៖ ចាស!ខ្ញុំមិនដែលទេ ខ្ញុំរត់មកឃើញតែម្ដង ។

វណ្ណៈ៖ ចឹងមានដឹងទេ ទំនប់ហ្នឹងគេលើកធ្វើអី?

ខុម ៖ មិនដឹងជាលើកធ្វើអីទេ ខ្ញុំរត់មកឃើញចឹងតែម្ដងហ្នឹងគេទំនប់គេល្មឹងល្មើយចឹងតែម្ដង តែបើបងខ្ញុំអាចដឹង ។

វណ្ណៈ៖ ចឹងកាល៧៩ហ្នឹងមីងមានចង់រត់ទៅផ្ទះដែរ?

ខុម ៖ ខ្ញុំចង់រត់ទៅផ្ទះដែរ តែរកផ្លូវមិនឃើញព្រោះខ្ញុំនឹកម៉ែពុកណាស់មិនដឹងជាទៅតាមផ្លូវណា ។

វណ្ណៈ៖ ចឹងមិនស្គាល់ផ្លូវរត់តាមគេវិញ?

ខុម ៖ ចាស!រត់តាមអង្គភាពវិញ ។

វណ្ណៈ៖ ចឹងពេលដែលរត់តាមផ្លូវមីងមានជួបការលំបាកយ៉ាងម៉េចទៅ?

ខុម ៖ កាលរត់តាមផ្លូវជួបការលំបាកណាស់ រត់តាមផ្លូវបំបែកចាន់គីរីហ្នឹងមកបានចូលទៅដីថៃ ។

វណ្ណៈ  បាទ ៗ

ខុម  :  ចូលដីថៃបានថៃណាស្រួលៗ ថៃណាពិបាកៗណាស់ដែរ   ថៃណាល្អៗ ថៃណាអាក្រក់តែអត់មានបាយហូបទេ៧៩ហ្នឹង ហូបតែបបរលាយត្រពាំង លាយដំឡូង ៗ

វណ្ណៈ  ចឹងកាលហ្នឹងមានដាច់ពេលទេ?

ខុម  :  អត់មានដាច់ទេ តែគ្រាន់តែមានបបរពាវៗ មានអង្ករមួយគ្រាប់ចឹងទៅ ៗ

វណ្ណៈ  ចឹងនៅពេលរត់ហ្នឹងមានឃើញមានមនុស្សស្លាប់ទេ?

ខុម  :  មានស្លាប់កូនក្មេងមនុស្សចាស់  តែខ្ញុំរត់តាមផ្លូវនេះស្រួលទេ  វាមិនសូវមានឡើងភ្នំដូចគេ  មានមនុស្សស្លាប់ច្រើនណាស់ដេកនៅស្តុកស្តឹងហ្នឹងហើយ ៗ

វណ្ណៈ  ចឹងមិនដឹងជាកូនពីណាពីណីទេ?

ខុម  :  ចាស!ជួនណាមានក្មេងមានចាស់    ជួនណាដាក់ចោលលើខ្ទមចឹងទៅមានទឹកបាយមួយដុំចឹងទៅដាក់ចោលចឹងរត់ទៅទៀតទៅ ទាំងគេទាំងឯងតែឈឺរត់ហើយ សែងហើយ ៗ

វណ្ណៈ  បាទ ៗ

ខុម  :  សែងគ្នាចូលដីថៃចឹងទៅ ខ្ញុំដើរហូតដល់ត្រាង ដល់ឡែនដល់ភ្នំកុយវ៉ាន់នោះ ទៅរកដំឡូងម៉ីយកមកហូប ដល់ដំឡូងម៉ីសៗ គេដាំចោលរាប់ឆ្នាំ ដើរដីកត្រពាំងដីកដំឡូង តែអត់បាយហូបទឹកម៉ែហើយ រត់ចឹងទៅមានបែកគ្នាហើយមកជួបគ្នាចឹងវិញហើយខ្ញុំហេវពេលហូបផ្លែល្ហុងព្រៃ ៗ

វណ្ណៈ  បាទ ៗ

ខុម  :  ចុះអត់មានបាយនោះ  ហូបទៅវាពុលក្អួត  ហូបត្រពាំងចឹងទៅពុលក្អួតខ្ញុំក្អួតជាងគេព្រោះខ្សោយ ៗ

វណ្ណៈ  ចឹងមីងជំនាន់ខ្មែរក្រហមមីងរៀបការហើយនៅ?

ខុម  :  នៅខ្ញុំមកការនៅបឹងបេងនេះ ៗ

វណ្ណៈ  រៀបការឆ្នាំណា?

ខុម  :  កាលឆ្នាំ៨១ ៗ

វណ្ណៈ  ចឹងរបៀបយ៉ាងម៉េច?

ខុម  :  កាលហ្នឹងនៅរៀបការចាប់ដៃ ដល់ការខ្ញុំហើយមានការសែនអីខ្លះ ៗ

វណ្ណៈ  ចឹងការចាប់ដៃម្តងមានប៉ុន្មានគូរ?

ខុម  :  ការខ្ញុំមាន៦គូរ ៗ

វណ្ណៈ  ចឹងកាលហ្នឹងអត់មានសុំការមួយគូរបានទេ?

ខុម  :  អត់មានសុំបានទេ ចាប់ការច្រើនគ្នាតែម្តង ៗ

វណ្ណៈ ចឹងអត់មានតាមការស្រឡាញ់ទេ?

ខុម ៖ មានសិទ្ធស្រឡាញ់គ្នាធម្មតា តែការជាច្រើនគួរយើងស្រឡាញ់ចិត្តនិងចិត្ត តែគ្រាន់មិនបានរៀបការ ក្រោយមកមានរៀបការមានសែនបានហូបចុកគ្រប់គ្រាន់ ។

វណ្ណៈ បាទ ។

ខុម ៖ ចាស!តែរីកចំរើនបន្តិចម្តងៗ កាលពីខ្ញុំនោះអត់សោះ សូម្បីតែភ្លើងអត់មានផងដុតចង្កៀងដុងៗ ចាប់ដៃគ្នាធម្មតាដូចជិនាន់ប៉ុល ពតចឹង ។

វណ្ណៈ ចឹងកាលហ្នឹងឆ្នាំ៧៩មីងមកដល់ម៉ាឡៃហ្នឹងតែម្តង?

ខុម ៖ ចាស!៧៩មកដល់ម៉ាឡៃ ។

វណ្ណៈ ចឹងកាលរត់មកមិនយូរទេ?

ខុម ៖ រត់កាលហ្នឹងម៉ាប្រាំងរហូតដល់ខែវស្សាយើងដើរនៅតាមព្រំដែនហ្នឹងរហូតបានចល័តៗបានធ្លាក់មកនៅម៉ាឡៃហ្នឹងបណ្តោយ ។

វណ្ណៈ ចឹងមកដល់ម៉ាឡៃហ្នឹងមានឃើញទេសភាពយ៉ាងម៉េច?

ខុម ៖ ម៉ាឡៃខ្ញុំរត់មកដល់ដំបូងខ្ញុំឃើញសុទ្ធតែព្រៃទាំងអស់ មានតែផ្លូវ៥០២មួយហ្នឹងឯង តែផ្លូវសុទ្ធតែព្រៃទាំងអស់ណែនដើរមិនចង់រួចទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានដើមឈើធំៗទេ?

ខុម ៖ ដើមឈើធំៗណាស់ ។

វណ្ណៈ ចឹងមើលថ្ងៃមិនចង់ឃើញទេ?

ខុម ៖ ចាស!មើលមិនឃើញទេ បានតែចូលហើយមើលមិនឃើញទេ មានតែម៉ាច្រកផ្លូវដើរហ្នឹង ។

វណ្ណៈ ចឹងមីងមកនៅក្នុងព្រៃចឹងមានអារម្មណ៍ខ្លាចទេ?

ខុម ៖ ខ្លាចដែរ តែមិនដឹងជាធ្វើយ៉ាងម៉េចព្រោះយើងមិនដឹងជារត់ទៅណា បើបែកអង្គភាពទៅខ្លាចអត់មានអីហូប ចឹងតាមអង្គភាពរហូតដល់ខ្ញុំរត់ៗទៅដល់គ្រាងគេបំបែកហើយគេថាបងប្អូនណាចង់ទៅស្រុកទៅភូមិគេឲ្យទៅ តែអាអ្នកថាទៅហ្នឹងមិនបានមកដល់ស្រុកទេ មិនដឹងជាទៅណា ខ្ញុំកាលហ្នឹងចង់មកដែរ ព្រោះនឹកម៉ែតែមិនហ៊ាន សម្រេចចិត្តមួយថាបើទៅខ្លាចមិនដល់ម៉ែ កាលហ្នឹងថៃបបួលទៅនៅជាមួយតែខ្ញុំមិនទៅ នឹកឃើញថាប្រទេសគេខ្ញុំមិនទៅទេ ។

វណ្ណៈ បាទ ។

ខុម ៖ អត់បាយស៊ីយ៉ាងម៉េចនៅស្រុកឯង នៅរួមរស់ជាមួយបងប្អូននៅអង្គភាពហ្នឹង មកស្រុកក៏មិនហ៊ានមកនៅខ្មែរ មកស្រុកមិនដឹងជាទៅតាមណា មិនដឹងស្រុកឯណាទេខ្ញុំមិនស្គាល់នោះ បើដឹងថាផ្លូវស្រួលមកកើតនោះខ្ញុំមកបាត់ហើយ ខ្ញុំមិននៅទេនឹកម៉ែចង់ស្លាប់ហើយអត់មានបាយហូប ។

វណ្ណៈ  បាទ ។

ខុម  :  កាលហ្នឹងដេកនឹកតែម៉ែ ។

វណ្ណៈ  ចឹងមកដល់ហ្នឹងគេរៀបចំយោធាទាំងប្រុសទាំងស្រីឬមួយស្រីៗគេឲ្យនៅខាងក្រោយ?

ខុម  :  ស្រីៗនៅដឹកជញ្ជូនពូៗធ្វើយោធា ។

វណ្ណៈ  ចឹងធ្វើយោធាហ្នឹងច្បាំងជាមួយទាហានយួន?

ខុម  :  ចាស ។

វណ្ណៈ  ចឹងនៅពេលច្បាំងគ្នាមានស្លាប់ទេ?

ខុម  :  មានស្លាប់ចឹងឯង ។

វណ្ណៈ  ស្លាប់ទាំងសងខាង?

ខុម  :  ស្លាប់ទាំងអស់គ្នាហ្នឹងឯង ។

វណ្ណៈ  ចឹងកាលហ្នឹងទាហានយួនស្លាប់ច្រើនទេ?

ខុម  :  កាលហ្នឹងមិនបានដឹងដែរ ខ្ញុំចេញពីព្រំដែនទៅចូលដីថៃ ព្រោះយួនដេញមកខ្លាំងរត់ចូលដីថៃ ទៅនៅថ្នល់ជាតិទី២ទី៣នោះ នៅសុទ្ធតែខ្មែរជុំរំខ្មែរយើង ។

វណ្ណៈ  បាទ ។

ខុម  :  ដល់យើងរត់នៅជុំរំបានប៉ុន្មានឆ្នាំទេ បានមកនៅដីខ្មែរវិញបានកើតជាមានស្រែមានភូមិមានដើមដូងអីហ្នឹង ។

វណ្ណៈ  ចឹងត្រឹមឆ្នាំ៨១-៨២ហ្នឹងមានរៀបការដូចជំនាន់ខ្មែរក្រហមដែរ?

ខុម  :  ចាស ។

វណ្ណៈ  ចឹងមានប្រមូលទ្រព្យសម្បត្តិដាក់រួមមានសហករណ៍អីទេ?

ខុម  :  អត់មានទេ ។

វណ្ណៈ  ចឹងពុថាតា សុន សេនចង់ប្រមូលទ្រព្យសម្បត្តិដាក់រួមនោះ?

ខុម  :  មានមែន ។

វណ្ណៈ  តែឆ្នាំណា?

ខុម  :  កាលហ្នឹងប្រមូលគោយន្តអីនោះ មុនយើងផ្តាច់ខ្លួនហ្នឹង ។

វណ្ណៈ  កាលផ្តាច់ខ្លួនឆ្នាំ៩៦?

ខុម  :  តែមុនហ្នឹងប្រមូលគោយន្ត គេថាធ្វើសង្គ្រាមតកូនចៅទៀត កុំតែបានផ្តាច់ខ្លួនទេកុំអីសង្គ្រាមតកូនចៅ ។

វណ្ណៈ  កាលហ្នឹងសុន សេនគាត់និយាយចឹង?

ខុម ៖ ចាស!អស់ពីឪពុកទៅមានកូនធ្វើតទៀតហើយ ។

វណ្ណៈ៖ ចឹងនៅតំបន់ម៉ាឡៃហ្នឹងមានពីណាជាអ្នកគ្រប់គ្រង?

ខុម ៖ គ្រប់គ្រងម៉ាឡៃហ្នឹងមានពីណាគេ មានតែសុខ ភាព ។

វណ្ណៈ៖ ឥឡូវគាត់ធ្វើធំដែរ?

ខុម ៖ ចាស!គាត់គ្រងខាងទាហាន ខាងប្រជាជនមានតា អៀង សារី ប៉ុល ពត ខៀវ សំផន តាម៉ុក ។

វណ្ណៈ៖ ចឹងតាម៉ុកកាន់នៅហ្នឹងដែរ?

ខុម ៖ តាម៉ុក កាលហ្នឹងកាន់ខាងជំនាវភ្នំឆត្រ ។

វណ្ណៈ៖ ចឹងនៅនេះ?

ខុម ៖ នៅនេះ តាអៀង សារី មិនដឹងជាពីណាខ្លះទេ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ៖ ចឹងទៅឆ្នាំណាសុន សេនចង់ប្រមូលជារួម?

ខុម ៖ មិនដឹងជាឆ្នាំណាទេ កាលហ្នឹងមានប្រមូលគោយន្ត ម៉ូតូអីតែកាលហ្នឹងមិនទាន់បានដាក់ជារួមទេ ។

វណ្ណៈ៖ កាលដែលគាត់ចង់ប្រមូលហ្នឹង មានអ៊ុនតាក់មកនៅ?

ខុម ៖ អ៊ុនតាក់អត់មានចូលមកដល់ហ្នឹងទេ តែកាលហ្នឹងប្រហែលជាឆ្នាំ៩០ជាង ខ្ញុំកាលហ្នឹងមិនដែលបានចាប់អារមណ៍រឿងហ្នឹងដែរ ។

វណ្ណៈ៖ ចឹងកាលហ្នឹងចង់ប្រមូលទ្រព្យសម្បត្តិប្រជាជន?

ខុម ៖ ចាស!តែមានពីណាសុខចិត្តមិនទាន់បានធ្វើអីទេ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមិនព្រម?

ខុម ៖ កាលហ្នឹងមិនទាន់បានធ្វើទេ ដល់ហើយយើងបានផ្តាច់ខ្លួនទាន់ទៅយើងបានធូរចឹងឯង ។

វណ្ណៈ៖ ចឹងនៅពេលដែលគាត់ចង់ប្រមូលទ្រព្យសម្បត្តិដាក់រួមហើយ បានប្រហែលជាប៉ុន្មានខែថ្ងៃបានជាគេបាញ់' សម្លាប់សុន សេនទាំងគ្រួសារ?

ខុម ៖ ខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ៖ ចឹងខាងកងទ័ពខ្មែរក្រហមតាំងពីឆ្នាំ១៩៧៩ដល់ពេលដាច់ខ្លួនខាងខ្មែរក្រហមកាលហ្នឹងទាហានមានប្រាក់ខែទេ?

ខុម ៖ ទាហានមិនដែលមានប្រាក់ខែទេ មានតែរបបហូប ។

វណ្ណៈ៖ ចឹងមានតែរបបហូប?

ខុម ៖ ចាស!របបហូបមិនចេះខ្វះ ។

វណ្ណៈ៖ ចឹងទាហានខ្មែរក្រហមវៃជាមួយយួននិងទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជាហ្នឹង តើមានទាហានមកពីខាងក្នុងសុំចុះចូលទេ?

ខុម ៖ មានសុំចុះចូលខ្លះ ។

វណ្ណៈ៖ ចឹងនៅពេលដែលទាហានខ្មែរក្រហមចាប់បានទាហានខាងក្នុងហ្នឹង ខាងខ្មែរក្រហមវៃធ្វើបាបដែរ?

ខុម ៖ អត់មានធ្វើបាបទេ ។

វណ្ណៈ៖ ចឹងបើទាហានខាងក្នុងចាប់បានទាហានខ្មែរក្រហមវិញមានដឹងថាធ្វើបាបទេ?

ខុម ៖ មិនបានដឹងផង ។

វណ្ណៈ៖ ចឹងកាលហ្នឹងម៉ាខ្ញុំមិនទាន់បានកើតជាស្រុកចឹងទេ?

ខុម ៖ ទើបតែផ្តាច់ខ្លួនហើយនេះ បានចាប់ដី យើងចេញពីដីថៃមក មកនៅតាមហ្នឹងដោះមីនអីហ្នឹងទៅចាប់ដីនៅចឹងតែម្តង ។

វណ្ណៈ៖ បាទ ។

ខុម ៖ ចាប់ដីចឹងមកដល់ឥឡូវបានដីស្រែដីចំការវាលអស់ហើយតាមហ្នឹង កន្លែងហ្នឹងសុទ្ធព្រៃឫស្សីព្រៃឈើ បើហួសទៅចឹងទៅដើមឈើច្រើណាស់ ។

វណ្ណៈ៖ ចឹងមានមីនច្រើន?

ខុម ៖ ចាស!កាលហ្នឹងដាក់ការពារនោះ ។

វណ្ណៈ៖ កាលហ្នឹងពីណាដាក់?

ខុម ៖ កាលហ្នឹងខ្មែរក្រហមដាក់ ។

វណ្ណៈ៖ ចឹងខ្មែរខាងក្នុងមានដាក់ទេ?

ខុម ៖ ខ្មែរខាងក្នុងកាលហ្នឹងដាក់នៅភ្នំវ៉ា ។

វណ្ណៈ៖ ចឹង?

ខុម ៖ បន្ទាយវានៅកន្លែងណាដាក់ត្រង់ហ្នឹងដែរ តែត្រង់យើងដាក់ការពារមិនឲ្យយួនចូលមក ។

វណ្ណៈ៖ ចឹងដាក់ទៅជួនកាលដាច់ជើងខ្លួនឯង?

ខុម ៖ ត្រូវមីនខ្លួនឯងខ្លះ ចឹងសព្វថ្ងៃនេះនៅតែមានផ្ទុះដែរ នៅមានចំអាត្រាក់ចំឡានផ្ទុះយើងមិនដឹងកន្លែងនោះ អ្នកដាក់ផ្សេងនោះ ជួនកាលអ្នកដាក់ស្លាប់ទៅ ។

វណ្ណៈ៖ ចឹងកាលមីងមកដល់ដំបូងគេហៅស្អីទៅ?

ខុម ៖ កាលមកដល់ដំបូងមិនដឹងជាគេហៅស្អីទេ ដឹងយ៉ាងម៉េចដល់ហើយពុគេហៅថាម៉ាខ្ញុំចឹងតែម្តងកាលដំបូងគេហៅភូមិដូង ។

វណ្ណៈ  ភូមិដូង?

ខុម  :  ចាស! កាលហ្នឹងមានខាងកាកបាទជួយបើអង្គអីនោះគេហៅភូមិដូងៗ ។

វណ្ណៈ  ចឹងមានខាងកាកបាទចូលមកជួយដែរ?

ខុម  :  ចាស ។

វណ្ណៈ  ចឹងកាលហ្នឹងយ៉ាងម៉េចបានជាមីងមិនរត់ទៅស្រុកក្រៅ?

ខុម  :  ខ្ញុំកាលហ្នឹងចង់ទៅដែលហ្នឹង តែបងមកយកទាន់ គ្រួសារខ្ញុំវ៉ាន់ហ្នឹងគាត់ចង់ទៅក្រៅដែរ តែបងខ្ញុំមួយមកយក កាលនោះគាត់កាន់កងវរៈដែរ ។

វណ្ណៈ  បាទ ។

ខុម  :  បានមកវិញមកនៅសព្វថ្ងៃហ្នឹង ខ្ញុំមុនដំបូងនៅបឹងបេង ដល់រត់ពីបឹងបេងមកនៅភូមិដូងយើងនេះ រត់ពីហ្នឹងចេញទៅនៅខ្វាវស្វាប់ ។

វណ្ណៈ  បាទ ។

ខុម  :  ចេញពីខ្វាស្វាប់មកបានមកនៅទីនេះសព្វថ្ងៃ ។

វណ្ណៈ  ចឹងបងដែលហៅមីងមកវិញហ្នឹងសព្វថ្ងៃគាត់នៅរស់ដែរ?

ខុម  :  នៅអូរសំព័រនិងបងខ្ញុំបង្កើតដែលនៅឲ្យជុំគ្នា ។

វណ្ណៈ  ចឹងនៅជុំគ្នាបើបានទៅអាមេរិចគ្រប់?

ខុម  :  ចាស! តែកាលហ្នឹងមានចិត្តមួយមិនចង់ដែរ ខ្លាចបែកស្រុកនិងខ្លាចម៉ែឪ យើងរត់ចឹងចង់នៅជុំគ្នាទេ ខ្ញុំរត់មកហ្នឹងបីនាក់បងប្អូន ។

វណ្ណៈ  បាទ ។

ខុម  :  ប្អូនពៅខ្ញុំមួយបងស្រីខ្ញុំមួយនិងខ្ញុំមួយបងប្រុសខ្ញុំនិងប្អូនប្រុសខ្ញុំនៅក្នុងទេ ។

វណ្ណៈ  ចឹងអត់មានឪពុកម្ដាយស្លាប់នៅក្នុងសម័យខ្មែរក្រហមទេ?

ខុម  :  អត់ទេ ឪពុកខ្ញុំគាត់មកឈឺទើបស្លាប់ដែរទេ ម៉ែខ្ញុំទើបស្លាប់បានមួយឆ្នាំហ្នឹងទេ ទើបធ្វើបុណ្យហើយ ។

វណ្ណៈ  ចឹងបងប្អូនទើបស្លាប់ក្រោយដែរ?

ខុម  :  ប្អូនខ្ញុំទើបស្លាប់ប្អូនស្រីមួយក្រោយម៉ែខ្ញុំមួយខែដែរ ហើយប្អូនប្រុសខ្ញុំមួយនោះស្លាប់នៅពេលឡើងដើមត្នោតខ្មែរក្រហមបាញ់ខ្ញុំមិនសូវដឹងទេ បងប្រុសខ្ញុំស្លាប់ខ្ញុំស្លាប់ត្រូវរបួសដែរ ស្លាប់ពីរនាក់មុន ។

វណ្ណៈ  ចឹងថានៅកន្លែងហ្នឹងមានសារគាំងអីហ្នឹង តើសម្ដេចសី ហនុយាងចូលនៅពេលណា?

ខុម  :  សារគាំងចូលមកខាងក្នុងនេះ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងមានបានទៅទទួលទេ?

ខុម ៖ ខ្ញុំបានទៅ តែទៅទទួលហ្នឹងមិនបានឃើញទេ ព្រោះមនុស្សយើងណាស់ ។

វណ្ណៈ៖ ចឹងមានមនុស្សច្រើន?

ខុម ៖ ច្រើនណាស់ប្រជ្រៀតចូលមិនបានទេ ខ្ញុំមិនសូវប៉ិនប្រជ្រៀត កាលហ្នឹងខ្ញុំមានកូនហើយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានមនុស្សប្រហែលប៉ុន្មាន?

ខុម ៖ កាលហ្នឹងមានមនុស្សរាប់រយរាប់ពាន់អ្នកដែលហ្នឹងណាស់ វែកគេវែកឯងទៅបានឃើញតែមួយភ្លែត ។

វណ្ណៈ៖ ចឹងកាលហ្នឹងច្រើនតែទ័ព?

ខុម ៖ កាលហ្នឹងមិនសូវមានពួៗផង មានតែប្រជាជននិងគ្រួសារទាហាន ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងមានដឹងថាមានអ្នកកាសែតមានភ្ញៀវបរទេសមកទេ?

ខុម ៖ ខ្ញុំមិនសូវដឹងផង ។

វណ្ណៈ៖ ចឹងមានដឹងថាសម្តេចយាងមកជិះអីមកទេ?

ខុម ៖ ខ្ញុំមិនបានដឹងដែរ កាលហ្នឹងចូលតាមដីថៃដឹង ខ្ញុំឈរចាំទទួលឃើញលោកមក គ្រាន់តែថាមកនាំគ្នាពូលគ្នានបានមើលអីឃើញទេ មនុស្សច្រើនមើលមិនឃើញទេ ។

វណ្ណៈ៖ ចឹងមីងគិតមើល កាលមីងមកដល់ម៉ាឡៃដំបូងនិងឥឡូវខុសគ្នាយ៉ាងម៉េច?

ខុម ៖ ពីដំបូងមកឥឡូវនេះខុសគ្នាឆ្ងាយណាស់ ។

វណ្ណៈ៖ ខុសយ៉ាងម៉េចទៅ?

ខុម ៖ ពីមុនមកសុទ្ធតែព្រៃយើងមានការហូបចុកមែន តែមិនដូចឥឡូវទេ កាលពីដើមយើងទិញពីថៃទាំងអស់ម្ហូបថៃស្អីថៃ ឥឡូវមានមកពីស្រុកយើងសព្វគ្រប់ កាលមុនយើងមិនទាន់ចេញចូលបាន យើងទិញមកពីថៃ តែម្ហូបត្រីមកពីថៃទាំងអស់ ឥឡូវអត់ទេ មានខ្មែរផងថៃផងយើងមានជ្រូកមានគោកាប់លក់ ។

វណ្ណៈ៖ ចឹងកាលសម័យតស៊ូមានម្ហូបអីមកពីណា?

ខុម ៖ ម្ហូបទិញថៃ មានត្រីខកំប៉ុង មានមីមានអីហ្នឹង មានប៊ីចេងស្ករមិនចេះខ្វះ ។

វណ្ណៈ៖ ចឹងមានសត្វព្រៃទេ?

ខុម ៖ មានពីណាមានគ្រួសារគេទៅមុនបាញ់បានមក តែគ្រួសារខ្ញុំមិនដែលទៅមុខទេ គាត់ពិការតាំងពីសម័យប្រជាជាតិ ។

វណ្ណៈ៖ ចឹងការមីងរៀបការជាមួយគាត់ គាត់ពិការហើយ?

ខុម ៖ ចាស!កាលហ្នឹងកុំអីមិនយកគាត់ដែល តែនឹកឃើញគាត់ពិការកាលសម័យហ្នឹង ខ្លាចទៅធ្វើទាហានទៅស្លាប់ចឹងយកប្តីពិការឲ្យហើយវាអនាគតបាន ឥឡូវបានរបស់ខ្ញុំមែន ។

វណ្ណៈ៖ ចឹងមីងគិតមើលមានសង្គ្រាមនិងអត់សង្គ្រាមយ៉ាងម៉េចដែរ?

ខុម ៖ កាលមានសង្គ្រាមពិបាកមែនហ្នឹងណាស់ សង្គ្រាមតកូនចៅយើងយ៉ាប់ ដល់អត់មានសង្គ្រាមចឹងសប្បាយយើងចង់ទៅណាក៏បាន ទៅស្រុកទៅលេងម៉ែឪអីស្រួលដែរ កាលកើតសង្គ្រាមខ្ញុំទៅលេងស្រុកយ៉ាប់ដែរហ្នឹង ទៅតាមផ្លូវប៉ោយប៉ែតយ៉ាប់ណាស់ ។

វណ្ណៈ៖ ចឹងមីងធ្លាប់ទៅលេងស្រុកប៉ុន្មានដង?

ខុម ៖ កាលហ្នឹងទៅលេងម៉ែកាលមិនទាន់ផ្តាច់ខ្លួននោះ ខ្ញុំទៅធ្វើបុណ្យបច្ច័យបួនបានមួយដងដែរ ។

វណ្ណៈ៖ ឆ្នាំណា?

ខុម ៖ មិនដឹងជាឆ្នាំណាទេ ។

វណ្ណៈ៖ កាលមីងចេញទៅខាងខ្មែរក្រហមមិនថាអីទេ?

ខុម ៖ អត់មានថាអីទេ តែយើងទៅខ្លាចតែពួកខាងនោះទេ កាលខ្ញុំទៅជិះឡានខ្ចុប តាមគោគត្បែងចេញតាមប៉ោយប៉ែត ។

វណ្ណៈ៖ ចឹងដល់ហ្នឹងយើងជិះឡាន?

ខុម ៖ ចាស!ជិះឡានទៅអត់មានអីទេ ។

វណ្ណៈ៖ ចឹងអត់មានអ្នកឆែកទេ?

ខុម ៖ អត់មានអីទេ ឲ្យតែផុតពីផ្លូវប៉ោយប៉ែតមិនមានអីទេ ផុតច្រកឆែកឆេរទៅអត់អីទេ យើងប្រឡំធ្វើជាអ្នករកស៊ីបាន តែយើងទៅមានសំពោងសំពាយមិនបានដែរ យើងពីនេះក៏មិនអីទៅដល់ស្រុកម៉ែហើយក៏មិនអីដែរ ។

វណ្ណៈ៖ ចឹងមានឡានចូលមក?

ខុម ៖ មានឡានត្រឹមប៉ោយប៉ែត ។

វណ្ណៈ៖ ចឹងដើរពីនេះទៅ?

ខុម ៖ អត់ទេ យើងចូលជិះឡានតាមដីថៃ ជិះឡានថៃមានម៉ូវ៉ា មានមេខ្យល់ថៃជូនទៅដល់ប៉ោយប៉ែតចឹងទៅ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងទៅមានគ្នាប៉ុន្មាននាក់?

ខុម ៖ ខ្ញុំទៅពីរនាក់បងខ្ញុំហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងគេចាយលុយអី?

ខុម ៖ កាលហ្នឹងចាយលុយថៃ ។

វណ្ណៈ៖ ចឹងជិះឡានទៅស្រុកទៅកំពង់ឆ្នាំង?

ខុម ៖ ទៅកំពង់ឆ្នាំងូវ ។

វណ្ណៈ៖ កាលហ្នឹងឡានជិះមាក់ប៉ុន្មាន?

ខុម ៖ មិនដឹងម្នាក់ប៉ុន្មានទេ ជិះឡានទឹសាន់ កាលហ្នឹងមិនមែនចេញទៅដល់ឯណា ចេញពីហ្នឹងទៅ ទៅដេកនៅបាត់ដំបង ចេញពីបាត់ដំបងបានទៅដល់ស្រុក ចុះផ្លូវពិបាកនោះ ។

វណ្ណៈ៖ ចឹងនៅពេលមកវិញខាងខ្មែរក្រហមមានចាប់អារម្មណ៍មឹងទេ?

ខុម ៖ កាលខ្ញុំមកម្តងយ៉ាប់ដែរ ខាងខ្មែរក្រហមយើងមិនចាប់ទេ ចាប់ខាងនោះចាប់ដកហូតលុយអស់តាំងពីនាឡិការអីយកអស់ កាលហ្នឹងមានខ្មោចឪខ្ញុំមកលេងខ្ញុំដែលកាលហ្នឹង កាលហ្នឹងវាចាប់ឪខ្ញុំដាក់ផ្សេង ខ្ញុំដាក់ផ្សេង តែវាមិនបានធ្វើបាបអីយើងទេ គ្រាន់តែវារកលុយនិងសួររកឯកសារផ្សេងៗ ខ្ញុំថាមិនដែលមានឯកសារអីផង បើយើងចូលទៅមានវ៉ាលីនិងកាសែតវាចាប់ បើយើងមានថង់រកស៊ីអីដូចជាអ្នករកស៊ីប៉ោយប៉ែតអីវាមិនចាប់ទេ ។

វណ្ណៈ៖ បាទ ។

ខុម ៖ កាលហ្នឹងចូលតាមផ្លូវហ្នឹងបានទៅស្រុក បើចូលទៅតាមផ្លូវនេះមិនបានទេ ។

វណ្ណៈ៖ ចឹងពេលមឹងទៅដល់ស្រុកមានគិតថាចង់នៅស្រុកវិញទេ?

ខុម ៖ ខ្ញុំចង់ដែរ កាលមិនទាន់ផ្តាច់ខ្លួនចង់សុំឪវារត់ដែលហ្នឹង តែពីនេះគេមិនឲ្យទៅ ព្រោះខ្ញុំពិបាកពេកវាលហ្នឹងមើលថានៅតែពិបាកតឹងតែងពេករត់ដែលហ្នឹង តែបានប៉ុន្មានគេផ្តាច់ខ្លួនបាននៅទីនេះរហូតទៅកុំអីខ្ញុំមិននៅហ្នឹងដែរហ្នឹង តែមុនហ្នឹងរត់ទៅពិបាកហើយមុនហ្នឹងទាក់ទងបានចេញ គេមិនចង់ឲ្យយើងទៅដែរ ។

វណ្ណៈ៖ បាទ ។

ខុម ៖ បើយើងចង់ទៅទាល់តែទាក់ទងខ្សែរយៈទើបយើងទៅបាន បើយើងចេញទៅគេចាប់បានក៏មិនបានដែរ មានអីកាលហ្នឹងប្រជាជនទៅវិញច្រើនដែរហ្នឹង សម័យហ្នឹងនៅតឹងដែរ ដល់យើងផ្តាច់ខ្លួនទៅបាននៅហ្នឹងគ្រប់គ្នា ។

វណ្ណៈ៖ ចឹងឥឡូវលែងចង់ទៅនៅស្រុកហើយ?

ខុម ៖ លែងចង់ហើយធ្លាប់នៅហ្នឹងហើយទៅនោះនឹកនេះ តែនៅនេះនឹកម៉ែនោះដល់ទៅលេងម៉ែស្រុកទៅនឹកផ្ទះសំបែងនៅនេះ ។

វណ្ណៈ៖ បាទ ។

ខុម ៖ យើងនៅយូរហើយយើងនៅតាំង៧៩ ។

វណ្ណៈ៖ ចឹងអត់មានចេតនាចង់ទៅនៅស្រុកវិញទេ?

ខុម : អត់មានទេ ។

វណ្ណៈ: ចឹងកូនចៅនៅទីនេះហើយ?

ខុម : ចាស! ណាមួយមានដីស្រែចំការនៅនេះហើយ ទៅស្រុកម៉ែចែកកូនអស់ហើយទៅនៅនោះអត់មានដីចែកទេ ម៉ែឪចង់បានឲ្យទៅនៅស្រុកដែរ តែមិនចង់ធ្លាប់នៅនេះហើយ បើថាដូចមុនចង់ដែលហ្នឹង ។

វណ្ណៈ: ចឹងតិចទៀតមានថ្នល់ជាតិទៅ?

ខុម : មានថ្នល់ជាតិលែងចង់ទៅទៀតហើយ ចឹងមានផ្លូវជាតិស្រួលហើយចង់ទៅស្រួលឥឡូវនៅពិបាកត្រង់កន្លែង៩៣នោះ ។

វណ្ណៈ: ចឹងកាលខ្មែរក្រហមធ្វើសមាហរណ៍កម្មនៅឆ្នាំ១៩៩៦ មីងមានអារម្មណ៍ភ័យឬមួយសប្បាយ?

ខុម : កាលហ្នឹងគិតថាមិនភ័យទេ មានចិត្តសប្បាយ បានត្រូវគ្នាចឹងសប្បាយបានទៅលេងស្រុកដួបម៉ែកំពង់តែនឹកស្រុកផង បើយើងមិនត្រូវគ្នាពិបាកចេញចូលទៅ បានផ្តាច់ខ្លួនចឹងបានជួយអរបានរួចផុតទុក្ខទោសពីសម័យនោះឯង ។

វណ្ណៈ: ចឹងតាមទស្សនៈមីងផ្ទាល់ដែលធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមតែមីងមិនសូវពិបាកទេ?

ខុម : ចាស!ខ្ញុំមិនសូវពិបាកទេ ។

វណ្ណៈ: តែកាលហ្នឹងមីងមានដឹងថាអកស្រុកអ្នកភូមិអីមានដឹងថាមានមនុស្សស្លាប់ឬអត់អាហារអីទេ?

ខុម : ដឹងខ្ញុំរត់កាត់ បើគេរត់កាត់តាមកោះកុងសំឡូតអាហ្នឹងបានមានលំបាកច្រើន ។

វណ្ណៈ: តែខ្ញុំចង់និយាយជំនាន់ខ្មែរក្រហមមានមនុស្សស្លាប់ដោយសារអត់បាយទេ?

ខុម : ខ្ញុំនិយាយកាលសម័យប៉ុល ពតមានសម្លាប់មនុស្សខ្ញុំនៅសៀមរាប គេមានមែនតែខ្ញុំមិនដែលឃើញគេសម្លាប់រាប់រយទេ ។

វណ្ណៈ: បាទ ។

ខុម : តែខ្ញុំនៅដាំបាយកន្លែងបងសំណាងហ្នឹង មានគេយកផ្នែកទោសមក ពីបីថ្ងៃមានមកមួយមកពីរយកមកដាក់ហ្នឹង ឲ្យយកបាយទៅឲ្យហូប ឲ្យពួកខ្ញុំយកបាយឲ្យហូបណាស់ ។

វណ្ណៈ: បាទ ។

ខុម : តែចំពោះខ្ញុំមួយ ខ្ញុំមិនហ៊ានធ្វើបាបគេទេ ។

វណ្ណៈ: បាទ ។

ខុម : ខ្ញុំយកបាយទៅខ្ញុំលាងចានស្រួបឲ្យមែន តែខ្ញុំមិនបានធ្វើបាបគេទេ តែមានអ្នកធ្វើការជាមួយខ្ញុំហ្នឹងយកបាយទៅឲ្យគ្នាចានអត់មានលាងដែរ ហើយស្តោះទឹកមាត់ដាក់ទៀត ខ្ញុំអត់ទេ ខ្ញុំមិនធ្វើបាបគេទេ ។

វណ្ណៈ  បាទ ។

ខុម  :  នឹកស្រណោះគេ  ទាំងគេទាំងខ្ញុំមិនធ្វើបាបគេទេ  តែដល់វេណខ្ញុំ  ខ្ញុំលាងស្អាតខ្ញុំញុំាំមែន  ញុំាំជាមួយសមូធម្មតា  តែបានតែពីរទៅបីថ្ងៃមិនដឹងជាគេយកទៅណា  ខ្ញុំមិនដឹងទេ ។

វណ្ណៈ  ចឹងនៅសៀមរាបហ្នឹងមានមន្ទីរឃុំឃាំងដែរ?

ខុម  :  មាននៅលើផ្ទះថ្មប្រជាជនហ្នឹងដឹងគេចាប់យកមកពីណាជួនកាលមានតែម្នាក់ពីរនាក់មិនដឹងមកពីណាទេ  គេអត់មានធ្វើបាបទេ ។

វណ្ណៈ  ចឹងចេះតែបាត់ជាបន្តបន្ទាប់?

ខុម  :  ចាស!ពីរបីថ្ងៃបាត់មានមកទៀត  តែពួកខ្ញុំហ្នឹងយកបាយឲ្យហូបតែមិនមានមនុស្សច្រើនទេ  មានតែពីរនាក់ម្នាក់ទេ  តែនៅបានតែពីថ្ងៃបាត់ ។

វណ្ណៈ  ចឹងមីងមានសង្កេតឃើញថាជាកម្មាភិបាលខ្មែរក្រហមដែលឬមួយជាប្រជាជន?

ខុម  :  មានស្រីមានប្រុសមិនដឹងជាយ៉ាងម៉េចស្លៀកពាក់ធម្មតា  យើងមិនបានចាប់អារម្មណ៍ដែរ ។

វណ្ណៈ  ចឹងកាលហ្នឹងនៅកន្លែងណាមីងមានចាំទេ?

ខុម  :  នៅលើផ្ទះម្តុំមាត់ស្ទឹងសៀមរាបនោះ ។

វណ្ណៈ  ចឹងនៅក្នុងឆ្នាំណាដែរ?

ខុម  :  មុនរត់យួន  កាលហ្នឹងប្រហែលជា៧៨ហ្នឹងឯង  ខ្ញុំកាលហ្នឹងនៅសៀមរាបបានប្រហែលជា៩ខែដែលទេ  ទើបមកនៅដែលហ្នឹង  នៅហើយរត់យួនបណ្តោយហ្នឹង ។

វណ្ណៈ  ចឹងកាលហ្នឹងអត់មានគ្នាច្រើនទេ?

ខុម  :  អត់មានច្រើនទេ ។

វណ្ណៈ  ចឹងហេតុអីហេតុអីបានជាខាងមន្ទីរមីងដាំបាយឲ្យអ្នកទោសហូប?

ខុម  :  ខ្ញុំមិនមែនដាំបាយឲ្យហូបទេ    តែមិនដឹងជាគេយកមកពីណាគេឲ្យពួកខ្ញុំយកបាយទៅឲ្យហូបផងទៅខ្ញុំមិនមែនដាំបាយឲ្យខាងហ្នឹងទេ  ខ្ញុំដាំបាយឲ្យពួកមន្ទីរពួកខ្ញុំទេណាស់  តែបាយមិនច្រើនទេ  ពីរនាក់បាយពីរចាន  តែអត់មានរាប់រយ១០ទៅ២០នាក់ដូចគេទេ ។

វណ្ណៈ  ចឹងប្រធានជាអ្នកយកបាយឲ្យ?

ខុម  :  ចាស ។

វណ្ណៈ  ប្រធានឈ្មោះអី?

ខុម  :  ឈ្មោះបង  ថេងតែមិនដឹងជាគាត់ទៅដល់ក្រហែងណាទេ  រត់៧៩បែកគ្នាអស់ហើយ ។

វណ្ណៈ  ចឹងបងថេនហ្នឹងកាចទេ?

ខុម  :  គាត់មិនកាចទេ  ធម្មតា ។

វណ្ណៈ៖ ចឹងដល់ពេល៧៩មីងរត់មកដល់ព្រំដែនតែម្តង?

ខ្ញុំ ៖ ចាស! រត់មកដល់ព្រំដែនតែម្តង ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងក៏ធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមមកចឹងណាស់ ចឹងមីងមិនសូវជួបការលំបាកដូចប្រជាជនទេ?

ខ្ញុំ ៖ ចាស ។

វណ្ណៈ៖ នារីនៅខាងស្រែអំបិលអី មានដាំបាយហូបឆ្អែត?

ខ្ញុំ ៖ តែខ្ញុំកាលនៅកងចល័តពិបាកណាស់ ហូបមិនគ្រប់គ្រាន់ទេ ហើយធ្វើការវាល់ល្ងាចទាំងយប់ទាំងថ្ងៃ ។

វណ្ណៈ៖ ចឹងទោះបីយ៉ាងណាប្រជាជននៅតាមជនបទអត់មានអាហារគ្រប់គ្រាន់និងមានប្រជាជនស្លាប់ច្រើនចឹង មីងគិតថាជាកំហុសមេដឹកនាំឬមួយជាកំហុសថ្នាក់ក្រោមតាមមីងយល់?

ខ្ញុំ ៖ មិបដឹងជាខាងណាស្រាប់តែឃើញគេបញ្ជាមកតែចឹង ថ្នាក់លើមិនដឹងថ្នាក់កណ្តាលមិនដឹងអត់ដឹងព្រោះឃើញតែគេបញ្ជាមកតែចឹងហើយ ខ្ញុំជិះពីកំពង់ឆ្នាំងតាមផ្លូវមកតាមសហករណ៍ឃើញហូបតែពោតទេ ។

វណ្ណៈ៖ បាទ ។

ខ្ញុំ ៖ ឃើញហូបតែពោតសុទ្ធអត់មានបបរអីទេ ព្រោះខ្ញុំឈប់សម្រាកនៅហ្នឹងឃើញតែចឹងឯង ។

វណ្ណៈ៖ ចឹងកាលហ្នឹងនៅសៀមរាបគណៈតំបន់ជាពីរណាមីងមានដឹងទេ?

ខ្ញុំ ៖ គណៈតំបន់ស្លាប់អស់ហើយ ឈ្មោះអ៊ឹសៀង ស្លាប់តាំងពី៧៩នោះរត់មកបងសំណាងក៏ស្លាប់នៅឆ្នាំ៧៩ហ្នឹងឯង ។

វណ្ណៈ៖ យ៉ាងម៉េចបានស្លាប់?

ខ្ញុំ ៖ ជិះឡានគេបាញ់ស្លាប់តាំង៧៩ ។

វណ្ណៈ៖ យ៉ាងម៉េចបានជាមីងដឹងថាគេបាញ់?

ខ្ញុំ ៖ ជិះឡានអាស្រ៊ីមមួយហ្នឹងឮគេថាបាញ់បេ បុកមួយគ្រាប់ទៅផាប់មួយឡានទាំងអស់ទាំងនិរសារអីហ្នឹង ។

វណ្ណៈ៖ បាទ ។

ខ្ញុំ ៖ ខ្ញុំដឹងតែចឹងឯងបើឲ្យខ្ញុំដឹងអីទៀតមិនដឹងទេ ។

វណ្ណៈ៖ ចឹងនៅពេលឥឡូវមានតុលាការហ្នឹង តាមចិត្តមីងគួរថាមានតុលាការឬមិនគួរមានតាមគំនិតមីងយល់ស្របឬមិនយល់ស្រប?

ខ្ញុំ ៖ មិនដឹងជាម៉េចទេខ្ញុំ តុលាការកាត់ក្តីខ្មែរក្រហមហ្នឹង?

វណ្ណៈ: បាទ!កាត់ក្ដីខ្មែរក្រហមហ្នឹងមានតុលាការអន្តរជាតិនិងតុលាការខ្មែរយើងចូលរួមគ្នាដើម្បីកាត់សេចក្ដីមេដឹកនាំកំពូល សព្វថ្ងៃហ្នឹងមានអឹះអៀង សារី អឹ អៀង ធិរិទ្ធ តា ខៀវ សំផន តា នួន ជា ។

ខុម : ចាស ។

វណ្ណៈ: មានឌុចអីហ្នឹង តែឌុចគេកាត់ទោសហើយនិងមានបួននាក់ទៀតគេកាត់គាត់នៅឆ្នាំក្រោយ នៅដើមឆ្នាំ២០១១នេះ?

ខុម : ចាស ។

វណ្ណៈ: ចឹងជាទស្សនៈរបស់មីងមានតុលាការកាត់ទោសហ្នឹងជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ នេះជាការយល់ឃើញរបស់មីង មីងគិតថាយ៉ាងម៉េចដែរ?

ខុម : ខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េច បើទីសខាងលើមកគេត្រូវធ្វើចឹង ធ្វើចឹងទៅគេចង់ធ្វើតុលាការកាត់ក្ដីតាមតែចិត្តគេទៅ គេចង់កាត់ទោសយ៉ាងម៉េចតាមតែគេទៅ តាមចិត្តខ្ញុំឲ្យគេកាត់ក្ដីទៅតែសម្រេចតាមគេកាត់ក្ដី ។

វណ្ណៈ: ចឹងមីងចង់ឲ្យមានតុលាការដែរ?

ខុម : ចាស!កាត់តាមស្របច្បាប់ឲ្យត្រឹមត្រូវ ។

វណ្ណៈ: ចឹងមីងជឿថាតុលាការជួយរកឃើញអ្នកមានកំហុសនិងជួយរកយុត្តិធម៌ឲ្យមីងបានត្រឹមត្រូវទេ?

ខុម : ខ្ញុំមិនដែលបានតាមដានផង ខ្ញុំមិនដែលបានមើលផង ដឹងថាគេកាត់ក្ដីតែបានត្រឹមត្រូវឬមិនត្រឹមត្រូវខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ: ចឹងមីងជឿជាក់ទេ តុលាការហ្នឹងមិនមែនជាតុលាការខ្មែរយើងសុទ្ធទេ ជាតុលាការចូលជាមួយអន្តរជាតិ តើមីងអាចជឿបានទេ?

ខុម : ចិត្តខ្ញុំវិញថា អ្នកមុនទៅបាត់ហើយអ្នកក្រោយរងទុក្ខតែឯងហ្នឹង ចឹងបានថាសុខចិត្តរំសាយឲ្យអស់តែម្ដង ។ «អ្នកអន្តុយជិតនិយាយ»

វណ្ណៈ: ចឹងអ្នកធំពីណាគេទៅបាត់?

ខុម : «អ្នកអន្តុយជិតនិយាយ» ចឹងដូចជាអ្នកធំៗក្ដាប់ពីលើគាត់ទៀតនោះ ។

វណ្ណៈ: ពីណាគេ?

ខុម : «អ្នកអន្តុយជិតនិយាយ»ដូចថា តាប៉ុល ពតងាប់អស់ហើយហ្នឹង ។

វណ្ណៈ: ចឹងពីណាទៀត?

ខុម : «អ្នកអន្តុយជិតនិយាយ» នៅសល់តែអឹះអៀង សារី ខៀវ សំផន ។

វណ្ណៈ: ប៉ុន្តែគាត់បន្ទាប់គ្នា?

ខុម ៖ "អ្នកអន្តុយជិតនិយាយ" គាត់បន្ទាប់គ្នាចឹងបានថា គាត់ចាស់ណាស់ទៅហើយរំសាយចោលឲ្យអស់ទៅអាហ្នឹងចិត្តខ្ញុំ ។

វណ្ណៈ អាហ្នឹងមិនអីទេ ជាទស្សនៈរបស់មីងទេ?

ខុម ៖ "អ្នកអន្តុយជិតនិយាយ" ចាស ។

វណ្ណៈ ហេតុអីបានជាមីងគិតថា រំសាយទៅវាមានប្រយោជន៍អីបានជាមីងចង់ឲ្យរំសាយ?

ខុម ៖ "អ្នកអន្តុយជិតនិយាយ" រំសាយទៅដូចថា ប្រជាជនផុតមូលហេតុផុតវេទនាគ្រោះអីហើយដល់បានមកវិញយើងសប្បាយ ទាំងអស់គ្នា កុំឲ្យយកបញ្ហាមកឲ្យរឹតតែឈឺក្បាលតទៅទៀត ។

វណ្ណៈ អានេះជាយោបល់របស់ប្រជាជនមិនមានបញ្ហាអីទេ ជាការយល់ឃើញ?

ខុម ៖ "អ្នកអន្តុយជិតនិយាយ" ចាស ។

វណ្ណៈ តែចិត្តមីងមានតុលាការក៏បាន?

ខុម ៖ ចាស!ល្អម្យ៉ាងដែរ តែត្រង់គាត់ក្តីយ៉ាងម៉េចខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ យ៉ាងម៉េចដែលពេលដែលមានតុលាការ?

ខុម ៖ មានតុលាការកាត់ក្តីវាបានដឹងខុសត្រូវ ។

វណ្ណៈ ចឹងមីងស្រុកម៉ាឡៃយើងវានៅឆ្ងាយពីភ្នំពេញ កាលពីមុនគេនិយាយថាខាងក្នុងខាងក្រៅអីចឹង?

ខុម ៖ ចាស ។

វណ្ណៈ ចឹងមីងគំនិតចង់ផ្សះផ្សារថា កុំឲ្យមានការបែងចែកថាជាតំបន់ខ្មែរក្រហមតទៅទៀតមីងចឹងទេ?

ខុម ៖ ចង់ គឺឲ្យមានការផ្សះផ្សារគ្នាឲ្យបានសប្បាយកុំឲ្យមានទំនាស់ទៅមុខទៀត ខ្ញុំបើបានចឹងវិញសប្បាយណាស់ បានត្រូវរ៉ូវគ្នាចឹងសប្បាយណាស់ ។

វណ្ណៈ ចង់ឲ្យមានខ្មែរតែមួយ?

ខុម ៖ ចាស ។

វណ្ណៈ កុំឲ្យមានថា ខាងនោះខ្មែរក្រហម?

ខុម ៖ ចាស!មិនចង់មានថាខ្មែរក្រហមខ្មែរក្នុងខ្មែរក្រៅ មុនគេថាចឹង គេថាកូនខ្មែរក្រហមមកទៀតហើយ ខ្ញុំថាខ្មែរក្រហមខ្មែរសអីសាច់ដូចតែគ្នាហ្នឹង ។

វណ្ណៈ បាទ ។

ខុម ៖ ខ្ញុំចង់ឲ្យមានខ្មែរតែមួយ មិនចង់ឲ្យថាអានេះចេះអានោះចុះ បើបានផ្សះផ្សារគ្នាល្អហើយខ្ញុំចូលចិត្តណាស់ ។

វណ្ណៈ បាទ ។

ខុម ៖ ចាស ។

វណ្ណៈ៖ ចឹងមីងមានចង់និយាយថែមទៀតទេ?

ខ្ញុំ ៖ អត់មានអីទេ ខ្ញុំមិនសូវចេះនិយាយផង ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

ខ្ញុំ ៖ ចាស ។

**«ចប់»**